សប្តាហ៍ទី 22

ដាវីឌ និងកូលីយ៉ាត

ដាវីឌយកឈ្នះ តាមរយៈសេចក្តីជំនឿលើព្រះជាម្ចាស់

រឿងក្នុងព្រះគម្ពីរ

កូលីយ៉ាតមានមាឌធំ និងកម្លាំងដ៏ខ្លាំង គ្មាននរណាអាចយកឈ្នះបានឡើយ។ ចំណែកដាវីឌមានមាឌតូច ហើយត្រឹមជាក្មេងប្រុសម្នាក់ តែដាវីឌ ជឿលើព្រះជាម្ចាស់។
ដាវីឌបានជឿថាព្រះគង់ជាមួយគាត់ ហើយបានយកឈ្នះកូលីយ៉ាតដោយខ្សែដង្កត់ និងក្រួសមួយដុំ។ បើយើងមានសេចក្តីជំនឿដូចជាដាវីឌ នោះទោះជាមានបញ្ហាអ្វីក៏យើងអាចយកឈ្នះបានដែរ។
ព្រះជាម្ចាស់ស្រឡាញ់យើង និងតែងតែគង់នៅជាមួយយើង។

សមិទ្ធផលសម្រេច





ដាវីឌមានជំនឿលើព្រះ ហើយបានយកឈ្នះកូលីយ៉ាតយ៉ាងក្លាហាន! ចូរយើងជឿលើព្រះ និងរស់នៅដោយសេចក្តីក្លាហានចុះ!

វត្ថុបំណង

- រៀនពីសេចក្តីជំនឿដែលជឿលើព្រះជាម្ចាស់ តាមរយៈសាច់រឿងដាវីឌ និងកូលីយ៉ាត
- តុបតែងខែល ដោយបណ្តុះចិត្តឱ្យមានជំនឿទុកចិត្តលើព្រះជាម្ចាស់ដូចដាវីឌ
- តុបតែងខែលផ្ទាល់ខ្លួន ដើម្បីបានបទពិសោធន៍ពីការច្នៃប្រឌិត និងអារម្មណ៍នៃមោទនភាពចំពោះស្នាដៃដែលខ្លួនបានសម្រេច។

សម្ភារៈ

- ចានក្រដាស
- ខ្មៅដៃពណ៌ ហ្វឺត/កូល័រទៀន
- កន្ត្រៃ
- ការ
- ស្ទីគ័រ /គ្រឿងតុបតែង
- ស្កុត (ឬស្កុតមុខពីរ)
- ក្រដាសពណ៌ (បើមាន)
- គំរូខែល
- ស្កុតពណ៌ (បើមាន)

របៀបធ្វើ

1 ការតុបតែងចាន



តុបតែងជាយចាន ដោយប្រើក្រដាសពណ៌ ឬជាត់ពណ៌ក៏បាន។

2 ការតុបតែងលម្អលើខែល



តុបតែងខែល ដោយប្រើហ្វឺត និងស្ទីគ័រ។

3 ការតុបតែងលម្អ



តុបតែងខែលឱ្យកាន់តែស្អាតដោយបិទរូបផ្កាយ រូបមកុដ រូបស្លឹកឈើ -ល-។

4 ការធ្វើដៃកាន់



បិតស្កុតផ្នែកខាងក្រោយនៃចាន ដើម្បីធ្វើជាដៃកាន់។

*ប្រើស្កុតមុខពីរក៏បាន។

5 រួចរាល់



"ខែលផ្ទាល់ខ្លួន" រួចរាល់! ជឿលើព្រះជាម្ចាស់ ហើយរស់នៅដោយក្លាហាន!

ការពង្រីកតំបន់សកម្មភាព

ការបង្កើត "កូឡាសខែលជំនឿ"

- ត្រៀមសម្ភារៈចម្រុះ(ក្រដាសពណ៌, អង្កាំសំប៉ែតផ្លេកៗ, ក្រណាត់, ឡេវ, ក្រដាសខ្ទប់កាដូរ។ល។)
- សរសេរ ឬបិទប្រយោគថា «ព្រះគង់នៅជាមួយខ្ញុំ!»។
- តុបតែង «ខែលផ្ទាល់ខ្លួន» ដោយសេរី ពីសម្ភារៈចម្រុះ។
- ដាក់តាំងខែលដែលបានធ្វើរួច រួចសរសើរគ្នាទៅវិញទៅមក។



Tip សម្រាប់គ្រូ

- សូមនិទានរឿងអំពីទិដ្ឋភាពមាឌដ៏ធំ និងកម្លាំងដ៏ខ្លាំងក្លារបស់កូលីយ៉ាត និងភាពក្លាហានរបស់ដាវីឌទៅកាន់កុមារ។
- សូមផ្តោតសំខាន់អំពីដាវីឌអាចឈ្នះបាន ដោយសារតែដាវីឌជឿលើព្រះជាម្ចាស់។
- សូមលើកទឹកចិត្តឱ្យកុមារសរសេរ ឬជ្រើសរើសរូបភាពដោយខ្លួនឯង។
- សូមប្រាប់កុមារ៖ "ខែលផ្ទាល់ខ្លួន" គឺជានិមិត្តសញ្ញាសេចក្តីជំនឿលើព្រះជាម្ចាស់។
- ក្រោយធ្វើរួច សូមលេងដើរតួយ៉ាងសប្បាយរីករាយដោយស្រែកថា៖ "ខ្ញុំក្លាហានដូចជាដាវីឌ!"។